# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**
**លេខ:** ០៩៩ **គ.ជ.ប.** ស.ស.រ

# សេចក្តីសម្រេច
## ស្តីពី
## ការធ្វើប្រតិភូកម្មអំណាចដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការចុះឈ្មោះជូនអ្នកបោះឆ្នោត ដែលជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែង សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ អាណត្តិទី៣ ឆ្នាំ២០១៩

## គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៥/០០២ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៩/០០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៥/៣២៧ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៥ ស្តីពីការតែងតាំងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៧/១១៦៩ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការតែងតាំងអនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជំនួសអនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលបានលាឈប់
- យោងស្មារតីអង្គប្រជុំគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៩
- យោងលិខិតលេខ ៤២៧ សជណ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ក្រសួងមហាផ្ទៃ។

## សម្រេច

**ប្រការ ១.-**

ត្រូវបានធ្វើប្រតិភូកម្មអំណាចដល់ក្រុមប្រឹក្សាឃុំ សង្កាត់ (កបឃ.ស) ឱ្យបំពេញតួនាទីជាតំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ក្នុងការចុះឈ្មោះបោះឆ្នោតក្នុងក្របខ័ណ្ឌការិយាល័យចុះឈ្មោះបោះឆ្នោតនៃអ្នកបោះឆ្នោតដែលជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែង ដែលនឹងប្រព្រឹត្តទៅចាប់ពី**ថ្ងៃទី០៤ ខែមីនា ដល់ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៩**។

**ប្រការ ២.-**

ក្នុងការអនុវត្តភារកិច្ចខាងលើ កបឃ.ស ត្រូវអនុវត្តតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន។

**ប្រការ ៣.-**

ដើម្បីអនុវត្តភារកិច្ច និងការទទួលខុសត្រូវនេះ កបឃ.ស ត្រូវទទួលបានធនធានសមស្រប ដែលរួមមានការបណ្តុះបណ្តាល ការកសាងសមត្ថភាព មធ្យោបាយ សម្ភារ ដែលផ្តល់ឱ្យដោយ គ.ជ.ប។

**ប្រការ ៤.-**

បន្ទាប់ពីរៀបចំបញ្ជីឈ្មោះសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ក្នុងមុខតំណែងរួចហើយ កបឃ.ស ត្រូវបញ្ជូនបញ្ជីនេះ តាមឋានានុក្រមទៅអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ និង អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ដើម្បីពិនិត្យ ផ្ទៀងផ្ទាត់ និងបញ្ជាក់ការឯកភាព។

**ប្រការ ៥.-**

គ.ជ.ប អាចដាក់ចេញសេចក្តីណែនាំជាក់ស្តែងបន្ថែមទៀតដល់ កបឃ.ស ក្នុងការចុះឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ។

**ប្រការ ៦.-**

ក្នុងការអនុវត្តភារកិច្ចដែលត្រូវបានធ្វើប្រតិភូកម្មអំណាចនេះ គ.ជ.ប នៅតែទទួលខុសត្រូវរួមលើដំណើរការនៃការចុះឈ្មោះបោះឆ្នោត និងអាចធ្វើអន្តរាគមន៍ក្នុងករណីចាំបាច់ទៅលើសកម្មភាពរបស់ កបឃ.ស ទាក់ទងនឹងការចុះឈ្មោះបោះឆ្នោត ដោយអនុលោមតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ បទបញ្ជា និងនីតិវិធី និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន។

**ប្រការ ៧.-**

អគ្គលេខាធិការដ្ឋាននៃ គ.ជ.ប គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត និង កបឃ.ស ត្រូវអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាព។

**ប្រការ ៨.-**

សេចក្តីសម្រេចនេះ មានអានុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃច័ន្ទ ១៣រោច ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែមីនា ឆ្នាំ២០១៩

**ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រធាន**

ស៊ិក ប៊ុនហុក

**ចម្លងជូន**

- ក្រសួងព្រះបរមរាជវាំង
- ក្រុមប្រឹក្សាធម្មនុញ្ញ
- ព្រឹទ្ធសភា
- រដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជូនជ្រាប"
- ដូចប្រការ៧ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ